ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS


# កិច្ចការស្រាវជ្រាវ

## ប្រធានបទ៖

# ការចូលជាធរមាននៃសន្ធិសញ្ញា


សាស្ត្រាចារ្យណែនាំ ៖ ឃឹម គីរី

រៀបរៀងដោយនិស្សិត ៖ ល.ស៊ុន ចាន់ដា ក.អ៊ុង សិទ្ធារ៉ែន

ក្រុម ៖ $L_3B_2$


ឆ្នាំសិក្សា ៖ ២០០៩-២០១០

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ មានសញ្ចេតនារំភើបរីករាយ និងមានកិត្តិយសជាខ្លាំង ដែលបានទទួលនូវឱកាសធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ក្រោមចំនងជើងថា **ការចូលជាធរមាននៃសន្ធិសញ្ញា** ដែលជាធាតុផ្សំមួយផងដែរក្នុងការបង្កើតអោយសន្ធិសញ្ញាមានសុពលភាព និង ចងភ្ជាប់កាតព្វកិច្ចព្រមទាំងបង្កើតសិទ្ធិដល់រដ្ឋជាសមាជិក ។

ប្រធានបទខាងលើនេះ ត្រូវបានយើងខ្ញុំទាំងអស់គ្នាយកមកធ្វើការពិភាក្សាវែកញែក ផ្តល់ជាមតិតាមពុទ្ធិរបស់ខ្លួនផ្ទាល់ តាមរយៈឯកសារក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យ និង ឯកសារក្រៅសាកលវិទ្យាល័យរួមជាមួយប្រភពមួយចំនួនទៀត រហូតបង្កើតបាននូវសមិទ្ធផលកិច្ចការស្រាវជ្រាវនេះឡើង ។

សមិទ្ធផលសម្រេចបានរបស់យើងខ្ញុំ ដែលបានស្រាវជ្រាវចងក្រងជាសៀវភៅនេះឡើងគឺយើងខ្ញុំបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ប៉ុន្តែទោះជាយ៉ាងណាក៏នៅតែមានកំហុសជាអចេតនា និង មិននឹកស្មានដល់ជានិច្ច ។

ក្រុមនិស្សិតយើងខ្ញុំ សូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងទាំងនោះ និង រង់ចាំជានិច្ចរាល់ការរិះគន់ក្នុងន័យស្ថាបនាជាបន្ថែមពីសំណាក់លោកគ្រូអ្នកគ្រូ អ្នកស្រាវជ្រាវក្នុងទិសដៅកែលម្អ នូវរាល់ខ្លឹមសារក្នុងសៀវភៅនេះ ។

ជាទីអវសាននេះយើងខ្ញុំសូមជូនពរលោកគ្រូអ្នកគ្រូ មិត្តអ្នកអានទាំងអស់ដែលបានយកចិត្តទុកដាក់លើកិច្ចស្រាវជ្រាវរបស់ក្រុមនិស្សិតខ្ញុំនេះ សូមឱ្យអស់លោកអ្នកទាំងអស់ជួបតែនឹងសំណាងល្អ ។

សូមគោពប្រសិទ្ធពរជ័យសិរីមង្គលកើតមានដល់លោកអ្នកគ្រប់ពេលវេលា ។

# មាតិកា

## សេចក្ដីផ្ដើម

I- **សញ្ញាណទូទៅនៃសន្ធិសញ្ញា** ............ ០២

១- និយមន័យ ............ ០២

**២-**ការព្រមព្រៀងមុនការចូលជាធរមាននៃសន្ធិសញ្ញា ............ ០២

ក- ការចរចារ ............ ០២

ខ- ការចុះហត្ថលេខា ............ ០៣

គ- ការផ្ដល់សច្ចាប័ន ............ ០៤

II- **ការចូលជាធរមាន** ............ ០៥

១- អានុភាពមុនពេលចូលជាធរមាននៃសន្ធិសញ្ញា ............ ០៥

ក- ការផ្ដល់សច្ចាប័ន ............ ០៦

ក.១- និយមន័យ ............ ០៦

ក.២- នីតិវិធីនៃការផ្ដល់ សច្ចាប័ន ............ ០៦

ក.២.១- ការផ្ដល់សច្ចាប័នតាមនីតិអន្តរជាតិ ............ ០៧

ក.២.២- ការផ្ដល់សច្ចាប័នតាមនីតិក្នុងស្រុក ............ ០៧

ក.២.៣- លិខិតតូបករណ៍សំរាប់ផ្ដល់សច្ចាប័ន ............ ០៨

ខ-ការភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញា (Accession) ............ ០៩

២- អានុភាពក្រោយពេលចូលជាធរមាននៃសន្ធិសញ្ញា ............ ១១

៣- លក្ខខ័ណ្ឌនៃការចូលជាធរមាននៃសន្ធិសញ្ញា ............ ១១

ក- ការយល់ព្រមភាគច្រើនពីរដ្ឋជាសមាជិកចូលរួម ............ ១២

ខ- កាលបរិច្ឆេទនៃការចូលជាធរមាននៃសន្ធិសញ្ញា ............ ១២

សេចក្តីសន្និដ្ឋាន និង យោបល់............................................................................................................ ១៤

ឯកសារយោង

# សេចក្តីផ្តើម

ការវិវត្តនៃមនុស្ស មានការផ្លាស់ប្តូរពីមួយដំណាក់កាលទៅមួយដំណាក់កាលដោយឥតឈប់ឈរ។ ដើមឡើយមនុស្សរស់នៅដាច់តែឯងដោយស្វែងរកចំណីអាហារដើម្បីចិញ្ចឹមជីវិតតាមរយៈ ការបរបាញ់ ការបេះផ្លែឈើ ការបរិភោគរុក្ខជាតិក្នុងព្រៃជាដើម។ ការរស់នៅបែបនេះ បានបង្កអោយ មានផលវិបាកយ៉ាងច្រើនដល់មនុស្សជាតិ ក៏ព្រោះថាបុគ្គលម្នាក់ៗត្រូវព្យាយាមជំនះនូវរាល់គ្រប់ឧបសគ្គដែលបានជួបប្រទះ។ ដោយហេតុនេះហើយ ទើបបុគ្គលម្នាក់ៗប្រមូលផ្តុំគ្នារស់នៅជាក្រុម ជាបក្សពួក ជាកុលសម្ព័ន្ធ ដោយព្រមព្រៀងគ្នា ហើយបានយល់ព្រមទទួលយកកិច្ចសន្យាសង្គម ដែល បង្កើតឱ្យមានច្បាប់សំរាប់គ្រប់គ្រងនៅក្នុងសង្គម និង មានបុគ្គលមួយរូប ឬ មួយក្រុមតូចធ្វើការគ្រប់គ្រងសង្គមទាំងមូល។ លុះបណ្តុំនៃមនុស្ស កើនឡើងកាន់តែច្រើនទៅៗ បានបង្កឱ្យមានកំនកំនើតនៃរដ្ឋនីមួយៗកើតឡើងនៅលើពិភពលោក។ យើងសង្កេតឃើញថា នៅក្នុងរដ្ឋនីមួយៗរមែងមានទំនាក់ទំនង ទៅវិញទៅមករវាងប្រជាជនរបស់ខ្លួន។ យ៉ាងណាមិញ ដូចគ្នានេះផងដែរ នៅក្នុងពិភពលោកយើងនាពេលបច្ចុប្បន្ននេះ ពុំមានរដ្ឋណាមួយអាចរស់នៅបានដោយគ្មានបង្កើតនូវទំនាក់ទំនងជាមួយនឹងរដ្ឋដទៃ បានឡើយ។ ហើយការធ្វើទំនាក់ទំនងនោះ ទោះបីជាស្ថិតនៅក្នុងរូបភាពតូចតាចក្តី ឬធំដុំក្តី ចាំបាច់ត្រូវ អនុលោមតាមច្បាប់ដែលតំរូវឱ្យបង្កើតឱ្យមានលិខិតុបករណ៍អន្តរជាតិនានា ដើម្បីជាភស្តុតាងបញ្ជាក់ អំពីការព្រមព្រៀងចំពោះការផ្លោះប្តូរទំនាក់ទំនងរវាងរដ្ឋ និង រដ្ឋនោះ។ ជាក់ស្តែង ការបង្កើត លិខិតុបរណ៍អន្តរជាតិនេះត្រូវឆ្លងកាត់នូវនីតិវិធីជាច្រើន ទំរាំតែ វាអាចមានអានុភាពគតិយុត្តក្នុងការ យកមកប្រើប្រាស់។ គួរឱ្យកត់សំគាល់ផងដែរ នៅក្នុងចំណោមនីតិវិធីក្នុងការបង្កើតលិខិតុបករណ៍ អន្តរជាតិទាំងឡាយនោះ យើងធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់ទៅលើការចូលជាធរមាន ដែលជាចំណុចចុងក្រោយបង្អស់ក្នុងការបង្កើតឱ្យមានកាតព្វកិច្ច និង សិទ្ធិចំពោះភាគីដែលជាសមាជិក។ ដូច្នេះ តើការចូលជាធរមាននោះ ស្តែងឡើងតាមនីតិវិធីដូចម្តេចខ្លះ?

# ការចូលជាធរមាននៃសន្ធិសញ្ញា

## I. សញ្ញាណទូទៅនៃសន្ធិសញ្ញា

### ១) និយមន័យ

នៅក្នុងសម័យទំនើបបច្ចុប្បន្ន សន្ធិសញ្ញាអន្តរជាតិ គឺជាប្រភពដ៏សំខាន់ និង មុនគេបង្អស់នៃនីតិអន្តរជាតិ។ សន្ធិសញ្ញាអន្តរជាតិ គឺជាកិច្ចព្រមព្រៀងទាំងឡាយ ដែលមានចរិតជាកិច្ចសន្យា ដែលធ្វើឡើង រវាងរដ្ឋ និង រដ្ឋ។

ចំពោះការកំណត់ពាក្យសន្ធិសញ្ញា ក៏ត្រូវបានធ្វើឡើងនៅក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់ នៃ សន្ធិសញ្ញា ឆ្នាំ១៩៦៩ ដែលបានកំណត់ថា *សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលធ្វើឡើងរវាង រដ្ឋ និង រដ្ឋ នៅក្នុងទំរង់លាយល័ក្ខអក្សរ ហើយស្ថិតនៅក្រោមនីតិអន្តរជាតិ។*

**កិច្ចព្រមព្រៀងទំរង់សាមញ្ញ**គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលចូលជាធរមាននៅពេលដែលចុះហត្ថលេខា រួចដោយមិនចាំបាច់រង់ចាំការផ្តល់សច្ចាប័នទេ។ ឧទាហរណ៍ : កិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃ២៣ ខែតុលា ឆ្នាំ ១៩៩១ ស្តីពីដំណោះស្រាយទូទៅជំលោះនៅកម្ពុជា។កិច្ចព្រមព្រៀងប្រភេទនេះ ត្រូវមានធាតុផ្សំដូចគ្នានឹងកិច្ច ព្រមព្រៀងអន្តរជាតិទូទៅដែរគឺត្រូវតែមាន ឯកសារសរសេរជាលាយល័ក្ខអក្សរ បញ្ជាក់ទីកន្លែង និង កាលបរិច្ឆេទ ការយល់ព្រមរបស់អ្នកទទួលបានអំណាចពេញសមត្ថកិច្ច និង មានអានុភាពបង្ខំ ហើយធ្វើឡើងក្នុងក្របខ័ណ្ឌនៃ នីតិអន្តរជាតិ។គេច្រើនប្រើកិច្ចព្រមព្រៀងប្រភេទនេះ ក្នុងទំនាក់ទំនងរដ្ឋបាល ឬ បច្ចេកទេស ឬ យុទ្ធសន្តិភាព។ ឧទាហរណ៍ : កិច្ចព្រមព្រៀងរវាងរដ្ឋបាលប្រៃសណីយ៍។ ផលប្រយោជន៍ដែលគេចូលចិត្តធ្វើកិច្ច ព្រមព្រៀង ប្រភេទនេះ គឺវាមានភាពងាយស្រួល និងរហ័សទាន់ចិត្តក្នុងការធ្វើនីតិវិធីចូលជាធរមាន។

**សន្ធិសញ្ញាពហុភាគីទូទៅ** ឬហៅម្យ៉ាងទៀតថាជាអនុសញ្ញាពហុភាគីទូទៅ គឺ ជាសន្ធិសញ្ញាដែលទាក់ទង វិធានទូទៅ នៃនីតិអន្តរជាតិ ឬ ស្តីពីផលប្រយោជនទូទៅនៃបណ្តារដ្ឋទាំងមូល។

### ២) ការព្រមព្រៀងមុនការចូលជាធរមាននៃសន្ធិសញ្ញា

#### ក) **ការចរចារ**

- តាមធម្មតាអ្នកដែលមានសមត្ថកិច្ចចរចារ ចាំបាច់ត្រូវមាននីតិសម្បទាក្រោមទម្រង់សរសេររបស់ អាជ្ញាធរ ដែលទទួលបាន (ប្រមុខរដ្ឋ) ទៅឱ្យតំណាងទូតម្នាក់។ យោងតាមមាត្រា ៧ នៃ អនុសញ្ញាទីក្រុង

វៀនបានចែងថា " ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស ប្រមុខបេសកកម្មទូត ត្រូវបាន នីតិសម្បទា" ។

- ការចរចារអាចធ្វើតាមច្រើនរបៀប ដូចជាការជជែកតាមផ្លូវការទូត តាមរយៈសន្និសិទពិសេស ឬ ការចរចារ ធ្វើឡើងក្នុងអង្គការអន្តរជាតិណាមួយ ។

- ភាគីចូលរួមលើកសំណើរលើអត្ថបទខ្លឹមសារ ហើយសំណើរត្រូវបានអនុម័តតាមសំលេងភាគច្រើន ។ រីឯ ភាសា គេច្រើនជ្រើសរើសយកភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ ( ភាសាអង់គ្លេស-បារាំង) ។

- សន្ធិសញ្ញាមានទំរង់ទូទៅ គឺ បុព្វកថា តួនៃសន្ធិសញ្ញា និង ឧបសម្ព័ន្ធ ។

ខ ) **ការចុះហត្ថលេខា**

រដ្ឋមួយអាចចាត់ទុកថាខ្លួនបានផ្តល់ការព្រមព្រៀងរបស់ខ្លួនលើសន្ធិសញ្ញា តាមរយៈការចុះហត្ថលេខា ។ យោង តាមមាត្រា ២ នៃអនុសញ្ញាទីក្រុងវៀនឆ្នាំ ១៩៦៩ បានចែងពីការព្រមព្រៀងរបស់រដ្ឋដែលតំរូវឱ្យគោរព តាមសន្ធិសញ្ញា អាចត្រូវបានស្តែងឡើងតាមរយៈការចុះហត្ថលេខារបស់អ្នកតំណាងនៅពេលដែលសន្ធិសញ្ញាចែង ថា ការចុះហត្ថលេខា និង មានអានុភាព ឬដោយហេតុថាវាត្រូវបានរដ្ឋចូលរួមចរចារបានព្រមព្រៀង ថាការចុះ ហត្ថលេខា និងមានអានុភាព ឬនៅពេលដែលគោលបំណងរបស់រដ្ឋដែលផ្តល់អានុភាពចំពោះ ការចុះហត្ថលេខា កើតចេញពីសិទ្ធិប្រទាន នៃអ្នក តំណាងខ្លួន ឬ ត្រូវបានធ្វើឡើងនៅក្នុងពេលចរចារ ។ ផ្អែកលើមាត្រានេះ ការព្រមព្រៀង ដើម្បីគោរពតាមសន្ធិសញ្ញា តាមរយៈហត្ថលេខា មានន័យថាធ្វើឱ្យសន្ធិសញ្ញាមាន ភាពត្រឹមត្រូវ ហើយរដ្ឋទាំងឡាយត្រូវទទួលស្គាល់នូវហត្ថលេខា របស់ខ្លួន ។

ការចុះហត្ថលេខា ជាការអនុវត្តអំណាច ដែលអ្នកតំណាងបានទទួលតាមរយៈសិទ្ធិប្រទាន ទោះបីជាការ ព្រមព្រៀងតាមរយៈការផ្តល់សច្ចាប័ន អាចជាវិធីដែលគេចូលចិត្តធ្វើក្នុងភាពជាក់ស្តែងក៏ដោយ ក៏ការព្រមព្រៀង តាមរយៈហត្ថលេខានៅតែមានសារៈសំខាន់ខ្លះដែរ ។ ការចុះហត្ថលេខា ជាធម្មតាវាជាកិច្ចការផ្លូវការមួយ ហើយ នៅពេលការចុះហត្ថលេខា មានការអាស្រ័យទៅលើការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តនោះ ការចុះ ហត្ថលេខាមិនបង្កើតឱ្យមានការព្រមពៀងដែលត្រូវអនុវត្តនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ការចុះហត្ថលេខា គឺជា មធ្យោបាយមួយនៃការបញ្ជាក់ពីភាពត្រឹមត្រូវ និង ការសំដែងឆន្ទះរបស់រដ្ឋហត្ថលេខីក្នុងការបន្ត ដំណើរការ សន្ធិសញ្ញា ។ ក្រោយពេលបានចុះហត្ថលេខា ឬ ការផ្លាស់ប្តូរលិខិតុបករណ៍រួច ភាគីនីមួយៗ មានកាតព្វកិច្ច ជៀសវាងរាល់ទង្វើ ទាំងឡាយដែលធ្វើអោយប៉ះពាល់ដល់កម្មវត្ថុ ឬ គោលបំណងនៃសន្ធិសញ្ញា បើមិនដូច្នោះទេ

រដ្ឋត្រូវ បញ្ជាក់ថាខ្លួនគ្មាន បំណងក្លាយជាភាគី នៃសន្ធិសញ្ញានេះ។ ការចុះហត្ថលេខា មានអត្ថន័យពីរយ៉ាងគឺ បញ្ជាក់ថា អត្ថន័យសន្ធិសញ្ញាពិតជា ត្រឹមត្រូវ និង ការចុះហត្ថលេខា ត្រូវបានចាត់ទុកជាការសន្យាហើយ មានតម្លៃសីលធម៌ នឹងក្លាយទៅជាស្ថាពរនៅពេល ដែលសន្ធិសញ្ញានោះត្រូវបានផ្តល់សច្ចាប័នរួច។

ចំពោះការចុះហត្ថលេខានេះ គឺមានតែបុគ្គលទេ ដែលមានសមត្ថភាពក្នុងការចុះហត្ថលេខា ពោលគឺបុគ្គល ដែលមានសមត្ថភាពចុះហត្ថលេខាមានដូចជា ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និង រដ្ឋមន្ត្រីការបរទេស។ ចំណែកឯ តំណាងរបស់រដ្ឋដែលមានសិទ្ធិប្រទាន អាចចូលរួចការចរចារ និងចុះហត្ថលេខាបានផងដែរ។ ជាធម្មតាការចុះ ហត្ថលេខា មិនធ្វើអោយសន្ធិសញ្ញាចូលធរមានភ្លាមនោះទេ ភាគច្រើនគេតែងតំរូវអោយមានការផ្តល់សច្ចាប័ន ថែមទៀត ទើប សន្ធិសញ្ញាចូលជាធរមានបាន។

ការចុះហត្ថលេខា ត្រូវធ្វើឡើងតាមរយៈពិធីជួបជុំណាមួយ។ រីឯ ឯកសារចុះហត្ថលេខាត្រូវដាក់លើតុ ក្នុងបន្ទប់ ប្រជុំដែលមានប្រតិភូទាំងឡាយ ដែលបានចូលរួមក្នុងការចរចារ។ ករណី សន្ធិសញ្ញាទ្វេភាគី អ្នកតំណាង នៃប្រទេសទាំងពីរ ចុះហត្ថលេខាបន្តបន្ទាប់គ្នា ឬតំណាលគ្នាទៅលើអត្ថបទសន្ធិសញ្ញា ឬលិខិតុបករណ៍ តែបើចំពោះ សន្ធិសញ្ញាពហុភាគីវិញ អ្នកតំណាងទាំងឡាយ អនុវត្តនូវរបៀបដូចគ្នា នឹងសន្ធិសញ្ញាពហុភាគីវិញ អ្នកតំណាង ទាំងឡាយ អនុវត្តនូវរបៀប ដូចគ្នា និងសន្ធិសញ្ញាទ្វេភាគីដែរ ក្នុងការចុះហត្ថលេខា។ អ្នកតំណាងត្រូវបានគេ ហៅឈ្មោះ អោយចុះហត្ថលេខាតាម លំដាប់តួអក្សរ។ ក្នុងការអនុវត្តន៏នៃការចុះហត្ថលេខាមានភ្ជាប់ដោយ ការបោះត្រាជាតិរបស់ភាគីនីមួយៗ នៅក្បែរហត្ថលេខា របស់អ្នកតំណាង ហើយការបោះត្រានេះ ត្រូវធ្វើឡើងនៅ ខាងឆ្វេងដៃនៃអ្នកតំណាង។

ក្នុងការអនុវត្តសន្ធិសញ្ញាពហុភាគី អ្នកតំណាងទាំងឡាយ មិនអាចចុះហត្ថលេខានៅថ្ងៃជាមួយគ្នាបានទេ ក្នុងករណីនេះសន្ធិសញ្ញាត្រូវបើកអោយមានការចុះហត្ថលេខាក្នុងចន្លោះពេលមួយដើម្បីអនុញ្ញាតអោយរដ្ឋាភិបាល ដែលមានចំណាប់អារម្មណ៏ បានសិក្សាពិចារណាទៅលើ អត្ថបទសន្ធិសញ្ញាតាមចំណង់ចំណូលចិត្ត មុនពេលចុះ ហត្ថលេខា។ លើសពីនេះទៅទៀតក៏មានសន្ធិសញ្ញាមួយចំនួនបើកចំហជាអចិន្ត្រៃយ៏ចំពោះរដ្ឋទាំងឡាយដើម្បីបាន ចូលរួមក្នុង សន្ធិសញ្ញានេះដែរ។

### គ ) ការផ្តល់សច្ចាប័ន

គឺជាការយល់ព្រមលើសន្ធិសញ្ញា ដោយអង្គការរបស់រដ្ឋ ដែលមានសមត្ថកិច្ច ដើម្បីឱ្យរដ្ឋជាប់កិច្ចសន្យាជា លក្ខណៈអន្តរជាតិបាន។

ក្រោយពីការចរចា និង ការចុះហត្ថលេខាដោយអាជ្ញាធរមានសមត្ថកិច្ចសន្យា ជាលក្ខណៈអន្តរជាតិជាមួយនឹងសន្ធិសញ្ញានេះ ពោលគឺអាជ្ញាធរ ផ្ទៃក្នុងមានសមត្ថកិច្ចផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញានេះដោយមានភ្ជាប់ជាមួយនូវកិច្ចជាឱឡារិកមួយបន្ថែម ដើម្បីបញ្ជាក់ពីការភ្ជាប់ខ្លួនរបស់រដ្ឋនោះ ទៅនឹងសន្ធិសញ្ញាណាមួយ។ ជាឧទាហរណ៍ ចំពោះប្រទេសកម្ពុជា រដ្ឋសភាអាចអនុម័ត យល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិបាន ហើយបន្ទាប់ពីការអនុម័ត របស់រដ្ឋសភាព្រះមហាក្សត្រ ប្រទានសច្ចាប័នលើសន្ធិសញ្ញា ឬ អនុសញ្ញា ឬ អនុសញ្ញាអន្តរជាតិ និង នៅចុងបញ្ចប់ លិខិតូបករណ ដែលបញ្ជាក់ថា កម្ពុជាព្រមផ្តល់សច្ចាប័ន ត្រូវផ្ញើទៅកន្លែងដាក់ដិកល់ សន្ធិសញ្ញា និង អគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ។

ការផ្តល់សច្ចាប័ន គឺជាការផ្តល់ការកំនត់ថារដ្ឋមួយបានក្លាយជាភាគី របស់សន្ធិសញ្ញាណាមួយ។ ក្នុងករណីការផ្តល់សច្ចាប័ន មិនត្រឹមត្រូវ សន្ធិសញ្ញា នងេត្រូវទុកជាមោឃ:បាន តែប្រសិនបើអនិយតភាព នៃសន្ធិសញ្ញាធ្វើឡើង នៅលើខ្លឹមសារជាក់ស្តែង ដូចជា ការរំលោភប្រាកដជាក់ លើបញ្ញត្តិនៃច្បាប់ផ្ទៃក្នុង ដែលជាវិធានជាមូលដ្ឋាននៃច្បាប់នេះ។ ការផ្តល់សចាប័ន គឺ ជាកិច្ច ឆន្ទានុសិទ្ធិ របស់រដ្ឋ ពោលគឺ រដ្ឋមានសេរីភាពគ្រប់គ្រាន់ក្នុងការបំពេញកិច្ចនេះ។ ប្រសិនបើរដ្ឋបដិសេធមិនព្រមផ្តល់សច្ចាប័ន រដ្ឋពុំមានការទទួលខុសត្រូវអ្វី ទាំងអស់ក៏ប៉ុន្តែរដ្ឋនោះ អាចទទួលរងនូវផលវិបាកនយោបាយផ្សេងៗ។ ឧ : សហរដ្ឋអាមេរិក បានបដិសេធ មិនព្រមផ្តល់សច្ចាប័ន ចំពោះ សហគមន អឺរ៉ុប ការពារជាតិ។

**II. ការចូលជាធរមាន**

បន្ទាប់ពីសន្ធិសញ្ញាត្រូវបានតាក់តែងរួច ភាគី រងចាំការចូលជាធរមាននៃសន្ធិសញ្ញា គឺរងចាំអោយសន្ធិសញ្ញា ក្លាយជាកាតព្វកិច្ចសំរាប់រដ្ឋទាំងឡាយជាភាគី និង ការអនុវត្តទៅវិញទៅមកតាមការព្រមព្រៀង។

**១) អានុភាពមុនពេលចូលជាធរមាននៃសន្ធិសញ្ញា**

- មុនពេលដែលសន្ធិសញ្ញាចូលជាធរមាន រដ្ឋនីមួយៗ មានកាតព្វកិច្ចជៀសវាងការអនុវត្តផ្សេងៗដែលធ្វើអោយប៉ះពាល់ ឬ ថយចុះនូវកម្មវត្ថុរបស់សន្ធិសញ្ញាជាដាច់ខាត។ មាត្រា ១៨ នៃអនុសញ្ញាទីក្រុងវៀន ១៩៦៩ តំរូវអោយមានកាតព្វកិច្ចនេះ នៅពេលដែលរដ្ឋជាភាគីបានចុះហត្ថលេខាដោយសន្ធិសញ្ញាដែល កំណត់អោយមានការផ្តល់សច្ចាប័ន។

- មាន ៦ មួយចំនួននៃសន្ធិសញ្ញាត្រូវបានអនុវត្តមុនពេលចូលជាធរមាន។ វាគឺជា ៦ ផ្លូវការទាក់ទងនឹងលក្ខខណ្ឌដែលតំរូវដល់រដ្ឋទាំងឡាយជាភាគីត្រូវបំពេញដូចជា : ការផ្តល់សច្ចាប័ន ការយល់ព្រម ការភ្ជាប់ខ្លួន . . . ។

**ក ) ការផ្តល់សច្ចាប័ន**

**ក.១ ) និយមន័យ**

ការផ្តល់សច្ចាប័ន គឺជាការសំដែងនូវការយល់ព្រមនៃរដ្ឋមួយចំនួនចំពោះការចងភ្ជាប់ខ្លួនទៅនឹងកាតព្វកិច្ច និង សិទ្ធិនៃសន្ធិសញ្ញា។ ( មាត្រា ២ នៃអនុសញ្ញាទីក្រុងវៀន)

ការផ្តល់សច្ចាប័ន ជាកិច្ចគតិយុត្តដើម្បីបញ្ជាក់បន្ថែមទៅលើសន្ធិសញ្ញាដែលអ្នកតំណាងបានចុះហត្ថលេខារួចហើយ។ ក្រោយការផ្តល់សច្ចាប័នរួចសន្ធិសញ្ញាអាចតំរូវអោយមានការផ្សព្វផ្សាយបន្ថែមទៀត ដើម្បីអោយសន្ធិសញ្ញា ត្រូវបានយកទៅអនុវត្តនៅទូទាំងប្រទេស ដូចជាការចុះក្នុងរាជកិច្ចជាដើម។

**ក.២ ) នីតិវិធីនៃការផ្តល់សច្ចាប័ន**

- នាពេលបច្ចុប្បន្ន សន្ធិសញ្ញាភាគច្រើនចូលជាធរមានក្រោយការផ្តល់សច្ចាប័នរួច។ ជាការពិតណាស់រដ្ឋនីមួយៗមានវិធានផ្ទៃក្នុងទាក់ទងនឹងការផ្តល់សច្ចាប័នដោយឡែកៗពីគ្នា តែទោះបីជាក្នុងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ផ្ទៃក្នុងរបស់រដ្ឋនីមួយៗខុសគ្នាយ៉ាងណាក៏ដោយក៏នៅមានលក្ខណៈរួមដូចគ្នាដែរ គឺការផ្តល់សច្ចាប័នតែងតែ ធ្វើឡើងតាមរយៈប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល។

- នៅពេលដែលការផ្តល់សច្ចាប័នមិនទាន់ធ្វើឡើងនៅឡើយទេ សន្ធិសញ្ញាមិនទាន់បង្កើតជាកាតព្វកិច្ចចំពោះ រដ្ឋនៅឡើយទេ លើកលែងតែកិច្ចព្រមព្រៀងមួយចំនួនដែលចូលជាធរមានត្រឹមតែការចុះហត្ថលេខា (សន្ធិសញ្ញាក្នុងទំរង់សាមញ្ញ)។ ម្យ៉ាងវិញទៀត ពេលមិនទាន់ផ្តល់សច្ចាប័នសន្ធិសញ្ញាអាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាបាន។

- ការផ្តល់សច្ចាប័នធ្វើឡើងនៅពេលដែល :

. សន្ធិសញ្ញាកំនត់ ឬ តំរូវអោយមានការផ្តល់សច្ចាប័ន។ ( មាត្រា ១៤ នៃអនុសញ្ញាវៀន)

. ដោយសារការព្រមព្រៀងរបស់រដ្ឋទាំងឡាយ ដោយយល់ថា គប្បីមានការផ្តល់សច្ចាប័ន លើសន្ធិសញ្ញាដើម្បីផ្តល់ភាពជឿជាក់ដល់ភាគីទាំងឡាយ។ ( មាត្រា ១៤នៃអនុសញ្ញាវៀន) ។

. អ្នកតំណាងរដ្ឋទាំងឡាយត្រូវបានចុះហត្ថលេខាលើសន្ធិសញ្ញាដែលទាមទារអោយមានការផ្តល់សច្ចាប័នរួចហើយហេតុនេះត្រូវតែមានការផ្តល់សច្ចាប័នជាចាំបាច់ ( មាត្រា ១៤នៃអនុសញ្ញាវៀន)

- នីតិវិធីនៃការផ្តល់សច្ចាប័នមានពីរ : គឺតាម នីតិអន្តរជាតិ និង នីតិក្នុងស្រុក ។

**ក.២.១ ) ការផ្តល់សច្ចាប័នតាមនីតិអន្តរជាតិ**

- រហូតមកដល់សព្វថ្ងៃ ការផ្តល់សច្ចាប័ននៅតែត្រូវបានគេអនុវត្ត វាជាទំរង់ផ្លូវការមួយដែលរដ្ឋអធិបតេយ្យ សំដែងនូវការយល់ព្រម ឬ បដិសេដពោលគឺប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាលអាចបដិសេដមិនផ្តល់សច្ចាប័ន ។

- ការផ្តល់សច្ចាប័នអនុញ្ញាត្តិអោយសភា ត្រួតពិនិត្យនូវការអនុវត្តនូវអំណាចរបស់ អំណាចនីតិប្រតិបត្តក្នុងការ បង្កើតសន្ធិសញ្ញា។ ម្យ៉ាងវិញទៀតក៏ធ្វើឡើងដើម្បីត្រួតពិនិត្យ ទៅលើអ្នកតំណាងថាតើ អ្នកតំណាងទាំងនោះបានអនុវត្ត ទៅតាមសិទ្ធិអំណាចដែលខ្លួនទទួលបានតាមរយៈសិទ្ធិប្រទាន បានត្រឹមត្រូវដែរ ឬ ទេ។

- តាមសេចក្តីសំរេចរបស់តុលាការយុត្តិធមិអន្តរជាតិក្នុងរឿងក្តី កំនត់ថា : ការផ្តល់សច្ចាប័ន លើសន្ធិសញ្ញាជា លក្ខខណ្ឌមួយមិនអាចខ្វះបាន ចំពោះការចូលជាធរមាននៃសន្ធិសញ្ញា ហើយជាកិច្ចគតិយុត្តមួយដ៏សំខាន់។

**ក.២.២ ) ការផ្តល់សច្ចាប័នតាមនីតិក្នុងស្រុក**

- នីតិវិធីនៃការផ្តល់សច្ចាប័នត្រូវបានកំនត់ដោយរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ហើយវាមានលក្ខណៈខុសៗគ្នា អាស្រ័យទៅតាមប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋ :

នៅក្នុងរបបសភានិយមជាញឹកញាប់មានការបែងចែកសមត្ថកិច្ចរវាងអំណាចនីតិប្រតិបត្តិ និង អំណាចនីតិបញ្ញត្តិ ដូចជានៅប្រទេសអង់គ្លេស និង បណ្តាប្រទេស common wealth សិទ្ធិប្រទានត្រូវចេញដោយប្រមុខរដ្ឋហើយប្រមុខរដ្ឋជាអ្នក ផ្តល់សច្ចាប័នដោយមិនចាំបាច់មានការអនុញ្ញាត្តពីសភាទេ ក៏ប៉ុន្តែការអនុវត្តនូវអំណាចនេះត្រូវស្របតាម វិធាន ដែល មានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែ ចំពោះសន្ធិសញ្ញាដែលមានសារសំខាន់ចាំបាច់ដូចជាសន្ធិសញ្ញាដែលទាក់ទង ទៅនឹង សិទ្ធិ និង កាតព្វកិច្ចរបស់ពលរដ្ឋ សន្ធិសញ្ញាព្រំដែន ត្រូវតែមានការចូលរួមពីអំណាចនីតិប្រតិបត្តិ។

នៅប្រទេសកម្ពុជា ការផ្ដល់សច្ចាប័នធ្វើឡើងដោយព្រះមហាក្សត្រ។ ព្រះមហាក្សត្រ ឡាយព្រះហស្ថលេខាលើ សន្ធិសញ្ញាដែលបានទទួលអនុម័តយល់ព្រមពីសភា ដូចដែលមានចែងក្នុងមាត្រា៩០ និង មាត្រា២៦ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។ មាត្រា ៩០ ចែងថា " រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយ បំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន។ រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់គេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និង ការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។ រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល។ រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។ **រដ្ឋសភា អនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ**។ រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម។ ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ រដ្ឋសភាបោះឆ្នោតទុក ចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។ មាត្រា ២៦ ចែងបានថា ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា។

នៅសហរដ្ឋអាមេរិច ប្រធានាធិបតីជាអ្នកផ្ដល់សច្ចាប័នដោយមិនចាំបាច់មានការចូលរួមពីសភាទេ ក៏ប៉ុន្តែចំពោះសន្ធិសញ្ញាដែលសំខាន់ត្រូវមានការយល់ព្រមពីសំលេង ពីរភាគបី នៃកូរ៉ុមរបស់ព្រឹទ្ធសភា។

នៅប្រទេសដែលប្រកាន់យករបបចំរុះដូចជាបារាំង បែលហ្ស៊ិច សន្ធិសញ្ញត្រូវបានគេបែងចែកជាពីរ គឺសន្ធិសញ្ញាមួយចំនួនមិនតំរូវអោយមានការចូលរួមពីសភាទេគឺប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាលជាអ្នកផ្ដល់សច្ចាប័ន និង សន្ធិសញ្ញាមួយចំនួនទៀតជាពិសេសសន្ធិសញ្ញាដែលទាក់ទងនឹងផលប្រយោជន៏ជាតិ ចាំបាច់ត្រូវមាន ការចូលរួមពីសភា ឧទាហរណ៏ ដូចជានៅក្នុងរដ្ឋធម្មនុញ្ញរបស់ បែលហ្ស៊ិក ១៨៣១ និង រដ្ឋធម្មនុញ្ញរបស់បារាំង ១៨៧៥ ១៩៤៦ និង ១៩៥៨។

### ក.២.៣ ) លិខិតុបករណ៏សំរាប់ផ្ដល់សច្ចាប័ន

ការផ្ដល់សច្ចាប័ន ត្រូវបានធ្វើឡើងតាមរយៈលិខិតូករណ៏ផ្ដល់សច្ចាប័ន រួចទើបផ្លាស់ប្ដូរលិខិតុបករណ៏ផ្ដល់សច្ចាប័ន សន្ធិសញ្ញានោះរវាងភាគី។

**- លិខិតតូបករណ៏ផ្ដល់សច្ចាប័ន**

- លិខិតុបករណ៍ផ្តល់សច្ចាប័ន ជាលិខិតផ្លូវការចេញដោយប្រមុខរដ្ឋ ដើម្បីប្រកាសផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាដែលបានចុះហត្ថលេខាដោយអ្នកតំណាង ដើម្បីអោយសន្ធិសញ្ញានោះចូលជាធរមាន។ វាជាឯកសារប្រូតូកូល ដែលមានផងដែរនូវការចុះហត្ថលេខារបស់ នាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីការបរទេស រួមទាំងត្រារបស់រដ្ឋ។ (នៅប្រទេសកម្ពុជាមានលិខិតុបករណ៍ផ្តល់សច្ចាប័នមួយចំនួនចុះហត្ថលេខាត្រឹមរដ្ឋមន្ត្រីការបរទេស)។

- ចំពោះការផ្តល់សច្ចាប័នលើសន្ធិសញ្ញាទ្វេភាគីលិខិតុបករណ៍ ត្រូវបានផ្ញើរក្នុងទំរង់ច្បាប់ដើមទៅអោយភាគីម្ខាងទៀត។

- ចំពោះសន្ធិសញ្ញាពហុភាគីវិញ លិខិតនេះក៏ត្រូវផ្ញើក្នុងទំរង់ច្បាប់ដើមដែរទៅអោយគ្រប់ភាគីលើក លែងតែសន្ធិសញ្ញាតំរូវអោយធ្វើចំពោះតែរដ្ឋាភិបាលហត្ថលេខីណាមួយ ឬ ចំពោះស្ថាប័នអន្តរជាតិណាមួយការផ្ញើធ្វើ តែមួយគត់ទៅតាមការកំនត់របស់សន្ធិសញ្ញា។

### ខ ) ការភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញា (Accession)

ក្រៅពីការចុះហត្ថលេខា និង ការផ្តល់សច្ចាប័ន គឺ ការភ្ជាប់ខ្លួនដែលជាមធ្យោបាយមួយសំរាប់ចងភ្ជាប់រដ្ឋ ឬ អង្គការអន្តរជាតិ ទៅនឹងសន្ធិសញ្ញាដែរ។

មាត្រា១៥ នៃអនុសញ្ញាទីក្រុងវៀន១៩៦៩បានចែងថាៈ ការយល់ព្រមរបស់រដ្ឋក្នុងការចងភ្ជាប់ខ្លួនទៅនឹងសន្ធិសញ្ញាតាមរយៈការភ្ជាប់ខ្លួនធ្វើឡើងបាននៅពេលដែលៈ

-នៅក្នុងសន្ធិសញ្ញានោះបានចែងថា ការសំដែងការយល់ព្រមរបស់រដ្ឋតាមរយៈការភ្ជាប់ខ្លួនអាចធ្វើបាន។

-ដោយសារការចរចាររវាងបណ្តាលរដ្ឋផ្សេងៗហើយបានយល់ព្រមអោយមានការភ្ជាប់ខ្លួន។

-គ្រប់ភាគីនៃអនុសញ្ញាយល់ព្រមអោយភ្ជាប់ខ្លួន។

ឧទាហរណ៍ នៅថ្ងៃទី៥ ឧសភា ១៩៧៨ ប្រទេស Nauru បាននាំមកនូវការភ្ជាប់ខ្លួនលើសន្ធិសញ្ញាទីក្រុងវៀនស្តីពីទំនាក់ទំនងការទូត។

នៅថ្ងៃទី១៣ ខែមេសា ១៩៧៨ ប្រទេស Loas បានចុះហត្ថលេខាភ្ជាប់ខ្លួនលើសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការហាមប្រាមការប្រើប្រាស់បច្ចេកទេសផ្សេងៗដែលប៉ះពាល់ដល់បរិស្ថាន ឆ្នាំ១៩៧៧ (The 1977 UN Convention on the prohibition of military or any other hostile use of environmental modification teachnic)

ការចូលរួមទៅក្នុងសន្ធិសញ្ញា (ជាពិសេសសន្ធិសញ្ញាពហុភាគី) អាចធ្វើឡើងតាមនីតិវិធីពិសេសម្យ៉ាង ហៅថានីតិវិធីនៃការភ្ជាប់ខ្លួន (La procedure de l'adhésion) ឬហៅម្យ៉ាងទៀតថាការភ្ជាប់ខ្លួន (Accession) ។

នីតិវិធីកៃការភ្ជាប់ខ្លួនគឺជានីតិវិធីមួយដែលតាមរយៈនីតិវិធីនេះរដ្ឋមួយ ដែលមិនបានចូលរួមក្នុងការចរចារ ក្លាយមកជាភាគីនៃសន្ធិសញ្ញាតាមរយៈសេចក្តីប្រកាសឯតោភាគីរបស់រដ្ឋនោះ ដើម្បីគាំទ្រនូវបណ្តារ ខ ទាំងឡាយ នៃសន្ធិសញ្ញានោះ ។

ការភ្ជាប់ខ្លួនធ្វើឡើងតាមរយៈលិខិតផ្លូវការ ជាចាំបាច់ទៅតាមការកំនត់របស់ច្បាប់ក្នុងស្រុក ដើម្បីធានា អោយបានច្បាស់លាស់ នូវការភ្ជាប់ខ្លួនរបស់រដ្ឋ ទៅក្នុងទំនាក់ទំនងអន្តរជាតិ ជាពិសេសត្រូវមានការយល់ព្រមពី សភា ។

ការភ្ជាប់ខ្លួនធ្វើឡើងតាមរយៈលិខិតតូបករណ៍ ដែលនឹងត្រូវបញ្ជូនទៅអាជ្ញាធរដែលមានសមត្ថកិច្ចរក្សា ទុកហើយលិខិតតូបករណ៍នោះត្រូវតែទទួលស្គាល់ដោយរដ្ឋទាំងឡាយជាភាគីនៃសន្ធិសញ្ញានោះ ។

នៅពេលដែលសន្ធិសញ្ញាមួយបានបើកអោយមានការភ្ជាប់ខ្លួន តាមរយៈការភ្ជាប់ខ្លួនពេលនោះ ការភ្ជាប់ ខ្លួនជាមធ្យោបាយតែមួយគត់សំរាប់រដ្ឋទាំងឡាយដែលចង់ចូលរួមក្នុងសន្ធិសញ្ញានោះ ។

ឧទាហរណ៍ៈ កាផ្តល់សច្ចាបន័ និង ការភ្ជាប់ខ្លួនរបស់ព្រះរាជាណាចក្រកម្ពុជាទៅនឹងអនុសញ្ញា ស្តីពីការ ការពារជីវិតក្នុងសមុទ្រ (InternationalConvention for the safety of life at sea បង្កើតនៅទីក្រុង London ថ្ងៃទី ១១ ខែវិច្ឆិកា ១៩៧៤) ដែលធ្វើឡើងនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ១៩៩៤ ចូលជាធរមានសំរាប់កម្ពុជាថ្ងៃទី ២៨ ខែ កុម្ភៈ ១៩៩៥ ។

**កំនត់សំគាល់:** លក្ខណៈខុសគ្នារវាងការផ្តល់សច្ចាបន័ និង ការភ្ជាប់ខ្លួនស្ថិតនៅត្រង់ៈ

-ការផ្តល់សច្ចាបន័ធ្វើឡើងចំពោះសន្ធិសញ្ញាដែលភាគីនោះបានចូលរួមតាក់តែងអត្ថបទនោះ ហើយផ្តល់ សច្ចាបន័ដើម្បី អោយសន្ធិសញ្ញានោះ ចូលជាធរមាន។ ការផ្តល់សច្ចាបន័ធ្វើឡើងតាមរយៈលិខិតតូបករណ៍ផ្តល់ សច្ចាបន័ (Instrument of Ratification/Instrument e Ratification) ។

-ការភ្ជាប់ខ្លួនធ្វើឡើងចំពោះសន្ធិសញ្ញា ដែលភាគីនោះមិនចូលរួមក្នុងការចរចារតាក់តែងអត្ថបទនោះទេ ហើយសន្ធិសញ្ញានោះស្ថិតនៅក្នុងកំឡុងពេលបើកអោយភ្ជាប់ខ្លួន។ ការភ្ជាប់ខ្លួនធ្វើឡើងតាមរយៈលិខិតតូបករណ៍ ភ្ជាប់ខ្លួន (Instrument of Accession/ Instrument de l'adhésion) ។

ពាក្យ ***ការយល់ព្រម*** (Aceptance/Aceptation ou Approbation) ត្រូវបានគេប្រើប្រាស់ច្រើននៅក្នុងសន្ធិសញ្ញាដើម្បីបង្ហាញពីការយល់ព្រមពេលខ្លះវាមានតំលៃផ្តល់សច្ចាបន័(Accession/Adhésion)ពេលខ្លះទៀតស្មើនឹងការផ្តល់សច្ចាបន័(Ratification/Ratifcation)។ ទោះបីជាយ៉ាង ណាក៏ដោយវាសំដៅទៅលើកិច្ចមួយដែលតាមរយៈកិច្ចនេះរដ្ឋណាមួយបានសំដែងការយល់ព្រមចងភ្ជាប់នឹងសន្ធិសញ្ញា។

**២) អានុភាពក្រោយពេលចូលជាធរមាននៃសន្ធិសញ្ញា**

ពេលខ្លះទោះបីជាសន្ធិសញ្ញាចូលជាធរមានក៏ដោយក៏វាមិនអាចអនុវត្តបានទាំងស្រុងដែរ។ ឧទាហរណ៍ករណី សន្ធិសញ្ញាទីក្រុងរ៉ូម ដែលបង្កើតគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុបដែលមានគោលដៅអភិវឌ្ឍន៍រយៈពេល ១២ឆ្នាំជា ៣ ដំណាក់កាល គិតចាប់ពី ១៩៧០ នៅក្នុងដំណាក់នីមួយៗមានខមួយចំនួនអាចអនុវត្តបាន ប៉ុន្តែការឆ្លងពីដំណាក់កាល មួយទៅតំណាក់កាលមួយទៀតធ្វើឡើងដោយសេចក្តីសំរេចពិសេសរបស់អង្គការនេះ ពោលគឺ រយៈពេលក្នុងដំណាក់ កាលនីមួយៗអាចត្រូវពង្រីក ឬ បង្រួម ពោលគឺការអនុវត្តពុំពេញលេញទេ។

**៣ ) លក្ខខ័ណ្ឌនៃការចូលជាធរមាន**

- **ចំពោះកិច្ចព្រមព្រៀងទំរង់សាមញ្ញ** : ការចូលជាធរមានបន្ទាប់ពីភាគីចរចារ ទាំងអស់បានសំដែងការយល់ព្រមចងភ្ជាប់ទៅនឹងសន្ធិសញ្ញាតាមរយៈការចុះហត្ថលេខា ហើយលក្ខខ័ណ្ឌនេះតែងតែមានបញ្ជាក់នៅក្នុង ខបញ្ចប់។

- **ចំពោះសន្ធិសញ្ញាផ្លូវការ** : វិធានទាក់ទងនឹងការចូលជាធរមានខុសគ្នាអាស្រ័យទៅតាមប្រភេទថា តើជា សន្ធិសញ្ញាទ្វេភាគី ឬពហុភាគី។

. <u>សន្ធិសញ្ញាទ្វេភាគី</u> : ចូលជាធរមាននៅថ្ងៃផ្លាស់ប្តូរលិខិតុបករណ៍ផ្តល់សច្ចាប័ន ឬ ការបង្កើត Proéces-verbal ដើម្បីផ្លាស់ប្តូរសច្ចាប័ន។ ដើម្បីផ្តល់ដល់រដ្ឋជាភាគីនូវពេលវេលាសំរាប់រៀបចំចូលជាធរមានសន្ធិសញ្ញាតែងតែមានចែងពី ការពន្យាពេលសំរាប់ការអនុវត្តការផ្លាស់ប្តូរសច្ចាប័ន។ ហើយប្រសិនបើលើសពីរយៈពេលនេះសន្ធិសញ្ញានឹងចូលជាធរមាន។ ក្នុងករណីតុល្លីភាព តុលាការយុត្តិធមិអន្តរជាតិ (ICJ) បានពិចារណាថាទុក ដូចជាចូលជាធរមាន។( **មាត្រា ២៤ វាក្យខ័ណ្ឌ២ នៃអនុសញ្ញាទីក្រុងវីយែន ១៩៦៩) ។**

**.** <u>សន្ធិសញ្ញាពហុភាគី</u> : ជាធម្មតាតំរូវអោយមានការផ្តល់សច្ចាប័នជាឯកច្ឆ័ន្ទ។ ឧទាហរណ៍ :

. មាត្រា ៣ កតិកាសញ្ញា Braind-Kellog (Pacte Brained-Kellog) ២៧ សីហា ១៩២៨

. មាត្រា ១២ សន្ធិសញ្ញា Bruxelles ១៧ មិនា ១៩៤៨ បង្កើតសហភាពអឺរ៉ុប

. មាត្រា១០ សន្ធិសញ្ញា Varsovie ១៤ ឧសភា ១៩៥៥

. មាត្រា ២៤៧ សន្ធិសញ្ញារ៉ូម ២៥ មិនា ១៩៥៧ ស្តីពីការបង្កើតគណៈកម្មការអឺរ៉ុប

### ក ) ការយល់ព្រមភាគច្រើនពីរដ្ឋជាសមាជិកចូលរួម

នៅពេលដែលភាគីមានចំនួនច្រើនពេក សន្ធិសញ្ញាអាចចូលជាធរមានដោយប្រទេសយល់ព្រមភាគច្រើន។ ប្រការនេះតែងមានកំនត់ក្នុងខចុងក្រោយនៃសន្ធិសញ្ញា។

ឧទាហរណ៍ : លក្ខន្តិកៈរបស់ក្រុមប្រឹក្សាអឺរ៉ុប ដែលចុះហត្ថលេខានៅទីក្រុង Londre ថ្ងៃទី ៥ ឧសភា ១៩៤៩ រវាងប្រទេស ១២ នៅអឺរ៉ុបចូលជាធរមានតាមមាត្រា ៤២ នៅពេលមានសច្ចាប័នទី៧។

អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ៤ វិច្ឆិកា ១៩៥០ ចូលជាធរមានក្រោយមានសច្ចាប័នទី១០ ( មាត្រា ៦៦ នៃអនុសញ្ញានេះ)

អនុសញ្ញាទីក្រុងវៀនស្តីពីច្បាប់សន្ធិសញ្ញា ១៩៦៩ ចូលជាធរមានក្រោយមានសច្ចាប័នទី ៣៥ កថាខ័ណ្ឌ១ ( មាត្រា៨៤ : អនុសញ្ញា នឹងចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃដែលមានការតំកល់នូវលិខិតុបរណ៍នៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិកទី ៣៥)។ ជាក់ស្តែង អនុសញ្ញានេះចូលជាធរមាន នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨០។

### ខ ) កាលបរិច្ឆេទនៃការចូលជាធរមាន :

សន្ធិសញ្ញាសម័យទំនើបភាគច្រើនកំណត់នូវ ខ ដែលទាក់ទងទៅនឹងកាលបរិច្ឆេទចូលជាធរមាននៅក្នុងបទបញ្ញត្ត។ ជាក់ស្តែង ចំពោះ :

- **សន្ធិសញ្ញាក្នុងទំរង់សាមញ្ញ** ភាគច្រើនកំនត់កាលបរិច្ឆេទចូលជាធរមាន នៅថ្ងៃចុះហត្ថលេខាតែម្តង។
- ចំពោះ **សន្ធិសញ្ញាទ្វេភាគី** កាលបរិច្ឆេទនៃការចូលជាធរមានមានតែមួយគត់ដែលបានកំណត់ ជាក់-លាក់នៅក្នុងបទបញ្ញត្ត។ ជាក់ស្តែង មាត្រា ៣ នៃ Agreement Providing for the Provisional Application of the Draft International Customs Conventions on Touring, on Commercial Vehicles and on the International Transportation of Goods by Road ដែលធ្វើឡើងនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី ១៦ មិថុនា ១៩៤៩ បានបញ្ជាក់ថា អនុសញ្ញានេះ ចូលជាធរមាន នៅថ្ងៃទី ១ មករា ឆ្នាំ ១៩៥០ ។ ប៉ុន្តែប្រសិនបើជា**សន្ធិសញ្ញាពហុភាគី**តែងមានការបែងចែកដាច់ពីគ្នា

រវាងការចូលជាធរមានរបស់ ភាគីដែលចូលរួមបង្កើតសន្ធិសញ្ញា និង កាលបរិច្ឆេទចូលជាធរមានចំពោះរដ្ឋទាំងឡាយ ដែលក្លាយជា ភាគីតាមរយៈការភ្ជាប់ខ្លួន។

## ***សេចក្តីសន្និដ្ឋាន និង យោបល់:***

មុននឹងឈានចូលទៅដល់ការចូលជាធរមាននៃសន្ធិសញ្ញា សន្ធិសញ្ញាត្រូវបានឆ្លងកាត់នូវដំណាក់កាលជាច្រើននៃដំណើការក្នុងការបង្កើតសន្ធិសញ្ញា។ ក្នុងដំណើរឆ្លងកាត់នេះបានបង្កើតឱ្យមានរូបភាពផ្សេងៗគ្នា នៃការចូលជាធរមាននៃសន្ធិសញ្ញាស្របពេលដែលសន្ធិសញ្ញាអាចដនឹងបង្កើតឡើងដោយរូបភាពជា ការចុះហត្ថលេខា កាដរផ្តល់សច្ចាប័ន ការផ្លាស់ប្តូរលិខិតតុបករណ៍ជាដើម ដែលអាស្រយ័ទៅតាមការកំណត់របស់ភាគីនៃសន្ធិសញ្ញា។ ពិនិត្យលើលក្ខ័ណ្ឌនេះ ឃើញថា ការចូលជាធរមាននៃសន្ធិសញ្ញា ជាការកំណត់មួយដែលបង្ហាញថាសន្ធិសញ្ញាមួយបានបង្កើត និង ត្រូវអនុវត្ត ពីត្រឹមពេលនេះតទៅចំពោះភាគីនៃសន្ធិសញ្ញានោះ។ ករណីនេះជាអញ្ញត្តកម្ម គឺវាមិនមានអានុភាពប្រតិសកម្មទេ។ ទោះជាមុនការចូលជាធរមាននៃសន្ធិសញ្ញា អាចមានអានុភាពមួយចំនួនតំរូវឱ្យភាគីអនុវត្តក៏ដោយ ក៏វាគ្រាន់តែជាលក្ខខ័ណ្ឌនៃការព្រមព្រៀងប៉ុណ្ណោះ ពុំមែនជាការអនុវត្តនូវ ខលក្ខខណ្ឌ័នៃសន្ធិសញ្ញាទាំងមូលទេ។ ទាំងនេះស្តែងឱ្យឃើញថាកម្មវត្ថុធំបំផុតរបស់ភាគីទាំងឡាយនៃសន្ធិសញ្ញាទោះជាសន្ធិសញ្ញាពហុភាគី ឬ ទ្វេភាគីក៏ដោយ ក៏នៅក្នុងដំនើរកាប្រព្រឹត្តិកម្មនៃសន្ធិសញ្ញាគឺជាអានុភាពក្រោយការចូលជាធរមាននៃសន្ធិសញ្ញា។ ហេតុនេះការ ចូលជាធរមានឥទ្ធិពលទៅលើកាតព្វកិច្ច និង សិទ្ធិនៃរដ្ឋជាភាគីថ្វីត្បិតតែគ្មានយុត្តាធិការណាអាចមកចាប់បង្ខំ រឺ ដាក់ទណ្ឌកម្មក៏ដោយ ក៏វាជាកិត្យានុភាព និង ការរក្សានូវចំនងមិត្តភាពល្អរវាង រដ្ឋ និង រដ្ឋផងដែរ។ ការដែលមិនគោរពតាមសន្ធិសញ្ញាដែលបានចូលជាធរមានរួយហើយនោះគឺជាការបន្ថោកនូវតំលៃជាតិខ្លួន ធ្វើឱ្យបាត់បង់នូវផលប្រយោជនជាតិ និង ភាពជានីតិរដ្ឋផងដែរ។ ដូចនេះដើម្បីទទួលបាននូវទំនុកចិត្តពីរដ្ឋនានា និង រក្សាបាននូវគុណតំលៃជាតិ ព្រមទាំងប្រយោជនជាតិ រដ្ឋជាភាគីនីមួយៗត្រូវពិនិត្យ ពិភាក្សាដោយប្រុងប្រយ័ត្ន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ទៅលើ រាល់លក្ខ័ខណ្ឌ័នៃសន្ធិសញ្ញាដែលកំពុងស្ថិតក្នុងដំណើរការប្រព្រឹត្តកម្ម ហើយប្រកាន់ភ្ជាប់នូវការអនុវត្តទៅតាម សន្ធិសញ្ញាដែលបានចូលជាធរមានចំពោះរដ្ឋខ្លួន។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៨
- អនុសញ្ញាទីក្រុងវៀនស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩
- សៀវភៅនីតិអន្តរជាតិសាធារណៈ រៀបរៀងដោយ : សាស្ត្រាចារ្យ អ៊ឹង រដ្ឋា
- សៀវភៅទំនាក់ទំនងអន្តរជាតិ រៀបរៀងដោយ : បណ្ឌិត ខៀវ ថរិកា
- របាយការណ៏កម្មសិក្សាបញ្ចប់ការសិក្សា ប្រធានបទ : លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ
  រៀបរៀងដោយ : និស្សិត ចេង សារុធ
- សៀវភៅច្បាប់អន្តរជាតិសាធារណៈ រៀបរៀងដោយ : បណ្ឌិត ឃឹម ឈុនអ៊ី
- http://www.untreaty.un.org/english/guide.ASP